ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN

លេខទី ០៩ ត្រីមាសទី៤ ឆ្នាំ ២០១៨ ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម A PUBLICATION OF THE DEPARTMENT OF AGRICULTURAL EXTENSION

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម / Department of Agricultural Extension




# បទពិសោធន៍ជោគជ័យរបស់ក្រុមហ៊ុន លី លី ហ្វ៊ូដ អ៊ីនដាសទ្រី ខូ អិលធីឌី

**អគារលេខ២៨១ ភូមិក្បាលដំរី សង្កាត់កាកាប ពោធិ៍សែនជ័យ រាជធានីភ្នំពេញ**

ព្រឹត្តប័ត្រព័ត៌មានកសិកម្មនេះ រៀបចំឡើងក្នុងគោលបំណងចងក្រងនូវរាល់បទពិសោធន៍ជោគជ័យផ្សេងៗ ដែលជាស្នាដៃអនុវត្តផ្ទាល់របស់កសិករ ក៏ដូចជាក្រុមហ៊ុន សហគមន៍ និងស្ថាប័នពាក់ព័ន្ធនានា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តការងារប្រចាំឆ្នាំ២០១៨ កន្លងមកនេះ និងធ្វើការផ្សព្វផ្សាយជូនដល់ប្រជាជាកសិករ និងដៃគូរពាក់ព័ន្ធ ដើម្បីជាចំណេះដឹងបន្ថែមសម្រាប់ការប្រកបរបរ ឬអាជីវកម្មពាក់ព័ន្ធនឹងវិស័យកសិកម្ម។

ព្រឹត្តិប័ត្រព័ត៌មានកសិកម្មនេះដែរ បានលើកយកបទពិសោធន៍ជោគជ័យ របស់ក្រុមហ៊ុនលី លី ហ្វ៊ូដ អ៊ីនដាសទ្រី ខូ អិល ធី ឌី តំណាងដោយកញ្ញា ជីន ស្រីមុំ មានទីតាំងស្ថិតនៅអគារលេខ២៨១ ភូមិក្បាលដំរី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជាក្រុមហ៊ុនឆ្នើមប្រចាំឆ្នាំ២០១៨ ដែលបានទទួលជ័យលាភី លើការងារធ្វើជំនួញតាមរយៈការបើកក្រុមហ៊ុនមកបង្ហាញជូនដូចខាងក្រោម៖

## ១- អំពីប្រវត្តិ

តាមការរៀបរាប់របស់កញ្ញា ជីន ស្រីមុំ បានឱ្យដឹងថា ក្រុមហ៊ុនលី លី ហ្វ៊ូដ អ៊ីនដាសទ្រី ខូ អិល ធី ឌី ក្នុងអំឡុងឆ្នាំ ២០០២-២០១០ ក្រុមហ៊ុនមានដីត្រឹមតែ ១០០០ ម៉ែត្រការ៉េ តែប៉ុណ្ណោះ លុះមកដល់ឆ្នាំ២០១១ ក្រុមហ៊ុនបានពង្រីកផ្ទៃដីដល់ទៅ៦៥០០ម៉ែត្រការ៉េ ដោយការធ្វើជំនួញចេះតែមានភាពល្អប្រសើរ និងទទួលបានការជួយគាំទ្រពីមួយថ្ងៃទៅមួយថ្ងៃ ធ្វើឱ្យក្រុមហ៊ុននាពេលបច្ចុប្បន្ននេះ បានពង្រីកខ្លួនលើផ្ទៃដីទំហំ ២០០០០ ម៉ែត្រក្រឡា ដោយបានកសាងជារោងចក្រសម្រាប់ផលិតនំស្រួយ លី លី នេះតែម្តង។



ស្ថានភាពអគារក្រុមហ៊ុនលី លី ហ្វ៊ូដ អ៊ីនដាសទ្រី ខូ អិល ធី ឌី ឆ្នាំ ២០០២-២០១០



ស្ថានភាពអគារក្រុមហ៊ុនលី លី ហ្វ៊ូដ អ៊ីនដាសទ្រី ខូ អិល ធី ឌី ក្នុងពេលបច្ចុប្បន្ន



១១.រក្សាទុក ១៨-២៤ម៉ោង



១២.សំងួត ទី២



១៣.រក្សាទុក៤០នាទី



១៤.ដុតនំ



១៥.បាញ់ប្រេង



១៦. លាយទឹកស្ករ



១៧.សំងួតទី៣



១៦.បាញ់ទឹកស្ករ



១៨.វេចខ្ចប់ដោយម៉ាស៊ីន



១៩.វេចខ្ចប់ដោយដៃ



២០.ស្តុកផលិតផលសម្រេច



២១. ការចែកចាយ

## ៤. ការអនុវត្តកិច្ចសន្យាផ្គត់ផ្គង់វត្ថុធាតុដើម

កញ្ញា ជិន ស្រីមុំ បានរៀបរាប់ប្រាប់ថា ក្នុងពេលបច្ចុប្បន្ន ក្រុមហ៊ុនបានធ្វើកិច្ចសន្យាជាមួយសហគមន៍ និងរោងម៉ាស៊ីនស្រូវធំៗមួយចំនួនក្នុងនោះមានដូចជា សហគមន៍ស្រូវ IBI ខេត្តកំពង់ធំ និងព្រះវិហារ រោងម៉ាស៊ីន ឡាយ សៃ រោងម៉ាស៊ីន ហ្គូដិនរាយ៍ រោងម៉ាស៊ីន ដូនកែវរាយ៍ រោងម៉ាស៊ីន ឡូរ៉ង់ រោងម៉ាស៊ីន បាត់ដំបងរាយ៍ រោងម៉ាស៊ីន ខ្មែរហ្វ៊ុត រោងម៉ាស៊ីន អែមរុារាយ៍ សហគមន៍ផ្គត់ផ្គង់ ពោត ដំឡូង និងសណ្តែកពីបណ្តាខេត្តមួយចំនួនទៀត។

កញ្ញា ជិន ស្រីមុំ បានបន្តទៀតថា ការអនុវត្តកិច្ចសន្យាផ្គត់ផ្គង់វត្ថុធាតុដើម ក្រុមហ៊ុនមានទម្រង់នៃកិច្ចសន្យា និងការចុះទស្សនកិច្ច ព្រមទាំងបានចុះធ្វើសវនកម្មផ្ទាល់ដល់ទីតាំងអ្នកផ្គត់ផ្គង់ច្បាស់លាស់ ដែលការងារទាំងនោះមានដូចជា ការចុះវាយតម្លៃ និងជ្រើសរើសពូជដំណាំកសិកម្មល្អជាដើម។





ចុះធ្វើសវនកម្មផ្ទាល់ដល់ទីតាំងអ្នកផ្គត់ផ្គង់





ចុះវាយតម្លៃនិងជ្រើសរើសពូជដំណាំកសិកម្មល្អ

## ៥- ផលិតផល និងការចែកចាយ

មកដល់ត្រង់ចំណុចនេះ កញ្ញា ជិន ស្រីមុំ បានបញ្ជាក់ប្រាប់ថា ផលិតផលរបស់ក្រុមហ៊ុនមានច្រើនប្រភេទ ក្នុងនោះមានដូចជា ប្រភេទនំគោ១០០ ប្រភេទនំគោ២០០ ប្រភេទនំប៉ោង៥០០ និងប្រភេទនំព្រិល ។

## ២- អំពីទស្សនវិស័យ និងគោលបំណង

កញ្ញា **ជិន ស្រីមុំ** បានឱ្យដឹងដែរថា ក្រុមហ៊ុនលី លី ហ្វ៊ូដ អ៊ីនដាសទ្រី ខូ អិល ធី ឌី ចង់ឃើញកម្ពុជា មានសមត្ថភាពផ្គត់ផ្គង់ផលិតផលម្ហូបអាហារដែលមានគុណភាព និងអនាម័យ ប្រកបដោយភាពជឿជាក់ និងមានគោលបំណងផ្តល់ឱកាសការងារដល់ប្រជាជនក្រីក្រ មិនចេះអក្សរ អសមត្ថភាព កំព្រា ខ្វះទីពឹង និងជួយដល់កសិករអាចដាំដុះដំណាំពោត និងដំណាំស្រូវ សម្រាប់ផ្គត់ផ្គង់ដល់ក្រុមហ៊ុន ដែលសកម្មភាពការងារនេះអាចជួយកាត់បន្ថយភាពក្រីក្រ ស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសអាចជួយកាត់បន្ថយការនាំចូលផលិតផលពីប្រទេសជិតខាង។

កញ្ញា **ជិន ស្រីមុំ** បានបន្តទៀតថា ដោយសារក្រុមហ៊ុនលី លី ហ្វ៊ូដ អ៊ីនដាសទ្រី ខូ អិលធីឌី មានទស្សនវិស័យ និងគោលបំណងច្បាស់លាស់នេះហើយ ទើបក្រុមហ៊ុនទទួលបានការគាំទ្រពីអង្គការជាច្រើន ក្នុងនោះមានដូចជា អង្គការផលិតភាពអាស៊ី(APO) យូនីដូ (UNIDO) អង្គការ JICA និងនៅឆ្នាំ២០១៣ ក្រុមហ៊ុនត្រូវបានជ្រើសរើសជាក្រុមហ៊ុនគំរូ ស្តីពីការអនុវត្តការពង្រឹងជាយុទ្ធសាស្ត្រនៃប្រព័ន្ធគាំទ្រសហគ្រាសធុនតូច និងមធ្យម ។

នៅពេលដែលក្រុមការងារបន្តសួរទៅកញ្ញា **ជិន ស្រីមុំ** ថា នៅមុនឆ្នាំ២០១៣ ធ្លាប់មានការគាំទ្របែបនេះដែរឬទេ? កញ្ញាឆ្លើយថា មាន ដូចជានៅក្នុងខែមិថុនា ឆ្នាំ២០០៨ អង្គការ IMPACT-កម្ពុជា បានជួយគាំទ្រផ្តល់ជាវីតាមីនសម្រាប់ដាក់បញ្ចូលទៅក្នុងនំ ក្នុងគោលបំណងជួយកាត់បន្ថយបញ្ហាពិការភាពរបស់កុមារ ដើម្បីជួយដល់សុខភាពកុមារកម្ពុជា។ ក្រោយមកនៅក្នុងខែសីហា ឆ្នាំ២០០៩ អង្គការ HAGAR ក៏បានជួយគាំទ្រ ដោយបានផ្តល់ជាម្សៅប្រូតេអ៊ីនសម្រាប់ដាក់បញ្ចូលទៅក្នុងនំ ហើយនឹងនៅក្នុងខែតុលា ឆ្នាំ២០០៩ អង្គការ GTZ និង BASF ក៏បានជួយគាំទ្រ ដោយបានផ្តល់ជាវីតាមីន អា (Vita minA) សម្រាប់ដាក់បញ្ចូលទៅក្នុងនំដើម្បីជួយដល់សុខភាពកុមារកម្ពុជាផងដែរ។

## ៣. ដំណើរការកែច្នៃ

កញ្ញា **ជិន ស្រីមុំ** បានរៀបរាប់ប្រាប់ថា ដោយសារដំណាំកសិកម្ម ដូចជា ស្រូវ ពោត សណ្តែក ដំឡូងនៅកម្ពុជាជាដំណាំមានសក្តានុពល ហើយមានការប្រមូលផលបានច្រើនលើសពីតម្រូវការ ធ្វើឱ្យកសិករលក់កសិផលបានតម្លៃទាប ដូច្នេះដើម្បីជួយលើកទឹកចិត្ត ដល់កសិករក្នុងការបន្តនិរន្តរភាពនៃការដាំដុះ ជំរុញទិន្នផលកសិកម្ម ឱ្យមានកំណើនខ្ពស់ និងកាត់បន្ថយការនាំចូលវត្ថុធាតុដើមពីបរទេស ក្រុមហ៊ុនលី លី ហ្វ៊ូដ អ៊ីនដាសទ្រី ខូ អិលធីឌី បានសម្រេចបង្កើតរោងចក្រផលិតនំស្រួយ លី លី នេះឡើង ដែលការផលិតត្រូវបានដំណើរការតាមខ្សែច្រវ៉ាក់ដូចខាងក្រោម៖


១.វត្ថុធាតុដើម


២.លាងអង្ករ


៣.ត្រាំអង្ករ


៤.កិនអង្ករ


៥.ចំហុយ


៦.លាយម្សៅ


៧.ប្របាច់ដុំម្សៅ


៨.សង្កត់ពុម្ពនំ


៩.សំងួតទី1


១០.ស្តុកផលិតផល១/២សម្រេច



ប្រភេទនំគោ១០០ និង ប្រភេទនំគោ២០០




ប្រភេទនំព្រិល




ប្រភេទនំ សម្រាប់នាំចេញ




ប្រភេទនំប៉ោង៥០០

កញ្ញា ជិន ស្រីមុំ បានបញ្ជាក់ប្រាប់ថា ផលិតផលដែលក្រុមហ៊ុនផលិតបាន ត្រូវបានបញ្ចេញលក់ទៅតាមបណ្តារាជធានី-ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា និងក្រៅប្រទេសផងដែរ។

## ៦- ការវិភាគសេដ្ឋកិច្ច

កញ្ញា ជិន ស្រីមុំ បានរៀបរាប់ប្រាប់ថាចំពោះប្រាក់ចំណូលរបស់ក្រុមហ៊ុនគិតជាមធ្យមស្មើនឹង ៧,៦២៨,៤៤១ ដុល្លារសហរដ្ឋអាមេរិក ក្នុង១ឆ្នាំ រីឯការចំណាយលើវត្ថុធាតុដើមស្មើនឹង៤,៣៤៨,២១១ដុល្លារសហរដ្ឋអាមេរិកក្នុង១ឆ្នាំ។

**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកៈ**

ក្រុមហ៊ុន លី លី ហ្វូដ អ៊ីនដាសទ្រី ខូ អិល ធី ឌី
អគារលេខ ២៨១ ភូមិ ក្បាលដំរី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទលេខៈ (៨៥៥) ២៣ ៦៧៩ ៩៩៩៩/២៣ ៦៨៩ ៩៩៩៩